**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ០៤ សរណន**

# សារាចរណែនាំ
## ស្តីពី
## ការរៀបចំខួប ១០០ឆ្នាំ របស់អង្គការអន្តរជាតិខាងការងារ ខួប ៥០ឆ្នាំនៃសមាជិកភាពរបស់កម្ពុជានៅអង្គការអន្តរជាតិខាងការងារ និងខួបអនុស្សាវរីយ៍លើកទី១៣៣ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩

អង្គការអន្តរជាតិខាងការងារ (ILO) ដែលជាទីភ្នាក់ងារត្រីភាគីឯកទេសផ្នែកពិភពការងាររបស់អង្គការសហប្រជាជាតិ ត្រូវបានបង្កើតនៅឆ្នាំ១៩១៩ ដើម្បីកំណត់បទដ្ឋានការងារ និងរៀបចំគោលនយោបាយនានា ក្នុងគោលបំណងបង្កើនយុត្តិធម៌សង្គម និងលើកកម្ពស់ការងារសមរម្យសម្រាប់ស្ត្រី និងបុរស។ បច្ចុប្បន្ន អង្គការអន្តរជាតិខាងការងារមានសមាជិកចំនួន ១៨៧ប្រទេស ដែលក្នុងនោះព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩។

ព្រឹត្តិការណ៍ខាងលើនេះ ក៏ស្របទៅនឹងខួបអនុស្សាវរីយ៍លើកទី១៣៣ នៃទិវាពលកម្មអន្តរជាតិ ១ឧសភា ដែលព្រះរាជាណាចក្រកម្ពុជាតែងបានរៀបចំប្រារព្ធយ៉ាងអធិកអធមជារៀងរាល់ឆ្នាំ។ ដើម្បីរៀបចំការប្រារព្ធខួប ១០០ឆ្នាំ របស់អង្គការអន្តរជាតិខាងការងារ ខួប៥០ឆ្នាំនៃសមាជិកភាពរបស់កម្ពុជានៅអង្គការអន្តរជាតិខាងការងារ និងខួបអនុស្សាវរីយ៍លើកទី១៣៣ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលសូមធ្វើការណែនាំ ដូចខាងក្រោម៖

១-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំកម្មវិធីខួប១០០ឆ្នាំ របស់អង្គការអន្តរជាតិខាងការងារ និងខួប៥០ឆ្នាំនៃសមាជិកភាពកម្ពុជានៅអង្គការអន្តរជាតិខាងការងារ ក្រោមប្រធានបទ "**បង្កើនយុត្តិធម៌សង្គម-លើកកម្ពស់ការងារសមរម្យ**" និងប្រកាសឱ្យប្រើប្រាស់កម្មវិធីការងារសមរម្យប្រចាំប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ និងខួបអនុស្សាវរីយ៍លើកទី១៣៣ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែឧសភា ឆ្នាំ២០១៩ ក្រោមប្រធានបទ "**កិច្ចគាំពារសង្គមដើម្បីផលិតភាព**" ដែលមានការចូលរួមពីតំណាងក្រសួង ស្ថាប័នរដ្ឋ តំណាងអង្គការវិជ្ជាជីវៈ តំណាងអង្គការជាតិ និងអន្តរជាតិជាដៃគូ។

២-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន សមាគមនិយោជក និងសហជីព ដើម្បីរៀបចំដំណើរការកម្មវិធី និងសកម្មភាព ដែលរួមមានជាអាទិ៍៖

- សិក្ខាសាលាត្រីភាគីស្តីពីការអនុវត្តច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីព
- កិច្ចពិភាក្សាជាន់ខ្ពស់អំពីអនាគតនៃការងារនៅកម្ពុជា
- ទិវាពលកម្មអន្តរជាតិ ១ ឧសភា ក្រោមប្រធានបទ "កិច្ចគាំពារសង្គមដើម្បីផលិតភាព"
- ទិវាជាតិស្តីពីសុវត្ថិភាព និងសុខភាពការងារ
- ទិវាជាតិស្តីពីទេសន្តរប្រវេសន៍ការងារ
- វេទិកាជាតិអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- វេទិកាការងារថ្នាក់ជាតិ
- កម្មវិធីរត់ម៉ារ៉ាតុងអបអរសាទរខួប១០០ឆ្នាំ របស់អង្គការអន្តរជាតិខាងការងារ និងខួប៥០ឆ្នាំនៃសមាជិកភាពកម្ពុជានៅអង្គការអន្តរជាតិខាងការងារ
- ការប្រកាសឱ្យប្រើប្រាស់របបសោធននិវត្តន៍
- យុទ្ធនាការលើកកម្ពស់ការផ្តល់សច្ចាប័ន និងការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ
- ការតាំងពិព័រណ៍សមិទ្ធផលនានាក្នុងភាពជាដៃគូអភិវឌ្ឍកម្ពុជាក្នុងរយៈពេល ៥០ឆ្នាំ របស់អង្គការអន្តរជាតិខាងការងារ
- ទិវាសហគ្រិនភាពកម្ពុជា
- ទិវាអន្តរជាតិពាក់ព័ន្ធមួយចំនួន ដូចជា ទិវាពិភពលោកលុបបំបាត់ពលកម្មកុមារ និងទិវាកម្មករការងារផ្ទះ
- ការផ្សព្វផ្សាយឱ្យបានផុលផុសអំពីសមិទ្ធផលនានា ក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់រាជរដ្ឋាភិបាល ក្រោមកិច្ចសហការជាមួយអង្គការអន្តរជាតិខាងការងារ
- គ្រប់សហគ្រាស គ្រឹះស្ថាន តំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្ម ត្រូវរៀបចំកម្មវិធីកម្សាន្តសប្បាយរបស់កម្មករនិយោជិតក្នុងឱកាសទិវាពលកម្មអន្តរជាតិ ១ ឧសភា
- ត្រូវសហការជាមួយដៃគូពាក់ព័ន្ធរៀបចំកម្មវិធីសម្រស់ឯកវាយនភណ្ឌ ឆ្នាំ២០១៩។

៣-ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន រដ្ឋបាលរាជធានី-ខេត្ត និងស្ថាប័នពាក់ព័ន្ធត្រូវសហការផ្សព្វផ្សាយសារាចរណែនាំ និងសារលិខិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ផ្តល់ថវិកា និងត្រូវធានារក្សាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ក្នុងឱកាសនៃការរៀបចំកម្មវិធី និងសកម្មភាពទាំងនោះ តាមភារកិច្ចរៀងៗខ្លួន។

៤-សាលារាជធានីភ្នំពេញ និងខេត្តទាំងអស់ក៏ដូចជាក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងសហគ្រាស គ្រឹះស្ថានឯកជន ត្រូវជ្រើសរើសទីតាំងសមស្រប ដូចជា ដងវិថីសំខាន់ៗ និងទីតាំងសហគ្រាស គ្រឹះស្ថាន ដើម្បីធ្វើការចងបដាពាក្យស្លោកតាមខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួប១០០ឆ្នាំ របស់អង្គការអន្តរជាតិខាងការងារ
- អបអរសាទរខួប៥០ឆ្នាំ នៃសមាជិកភាពកម្ពុជានៅអង្គការអន្តរជាតិខាងការងារ
- អបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៣ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា
- បង្កើនយុត្តិធម៌សង្គម-លើកកម្ពស់ការងារសមរម្យ
- សន្តិភាពយូរអង្វែងផ្អែកលើយុត្តិធម៌សង្គម
- ការងារសមរម្យ កសាងសន្តិភាព និងស្ថិរភាព
- ការងារសមរម្យជាចលករនៃការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងចីរភាព

- ការងារសមរម្យជាមូលដ្ឋានគ្រឹះនៃសង្គមដែលមានយុត្តិធម៌ ផលិតភាព និងបរិយាប័ន្ន
- ការងារសមរម្យកសាងលើមូលដ្ឋានត្រីភាគី និងកិច្ចសន្ទនាសង្គម
- សន្តិភាព ស្ថិរភាព ដើម្បីការងារ និងមុខរបរ
- គោរពច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីព ដើម្បីជានាសិទ្ធិ និងផលប្រយោជន៍រួមរបស់កម្មករ និយោជិត និងនិយោជក
- ចូលរួមយុទ្ធនាការគ្រោះថ្នាក់ការងារកម្រិតសូន្យ
- អភិវឌ្ឍរបបសន្តិសុខសង្គម ដើម្បីសុខុមាលភាពសង្គម
- អភិវឌ្ឍជំនាញវិជ្ជាជីវៈ ដើម្បីផលិតភាព និងភាពប្រកួតប្រជែង។

រាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និយោជក កម្មករនិយោជិតទាំងអស់ ចូលរួមប្រារព្ធ និងអបអរសាទរកម្មវិធីខួប១០០ឆ្នាំ របស់អង្គការអន្តរជាតិខាងការងារ ខួប៥០ឆ្នាំនៃសមាជិកភាពកម្ពុជានៅអង្គការអន្តរជាតិខាងការងារ និងខួបអនុស្សាវរីយ៍លើកទី១៣៣ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩ ក្នុងបរិយាកាសសោមនស្សរីករាយ សាមគ្គីភាព និងភាតរភាព ដើម្បីឱ្យស័ក្តិសមសម្រាប់ព្រឹត្តិការណ៍ដ៏មានសារសំខាន់នេះ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានី-ខេត្ត ត្រូវរៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ចន្ទ ៥ រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មីនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ